ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៖១២
ចុះថ្ងៃទី០២/០១/២០១៣

សាលដីកា
លេខ ៖ ៧១ "ក្រIVច"
ចុះថ្ងៃទី ២៧/១១/២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ: ០៦ក្រ ចុះថ្ងៃទី ០៨.០២.១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៧/១១/២០១៣ ដោយមាន ៖

## សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

## ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៖ ១២ ចុះថ្ងៃទី០២/០១/២០១៣ រវាង៖

-ជនជាប់ចោទឈ្មោះ [redacted] សុផល ភេទ ប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ កងទ័ព ទីកន្លែងកំនើតនៅភូមិគោកដូង ឃុំពួក ស្រុកពួក ខេត្តសៀមរាប ទីលំនៅមុនពេលឃុំ [redacted] ស្រុកពួក ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] មានកូន ០៤នាក់ ឪពុកឈ្មោះ [redacted] "វ" ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន។

ឃុំខ្លួនបណ្តោះអាសន្នចាប់ពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១១ នៅពន្ធនាគារខេត្តសៀមរាប។

-ជនជាប់ចោទឈ្មោះ [redacted] សៅរី ហៅ បូរី ភេទ ប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិគោរដ្ឋាន ឃុំអូរអំបិល ស្រុកសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ មានទីលំនៅមុនពេលចាប់ខ្លួននៅ/

៧១៧

[redacted] ស្រុកពួក ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] "វ" ម្ដាយឈ្មោះ [redacted]" ទោសពីមុនគ្មាន។

ឃុំខ្លួនបណ្ដោះអាសន្នចាប់ពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១១ នៅពន្ធនាគារខេត្តសៀមរាប។

-ជនជាប់ចោទឈ្មោះ [redacted] សីហា ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិគោកថ្មី ស្រុកពួក ខេត្តសៀមរាប សាសនាព្រះពុទ្ធ មានទីលំនៅមុន [redacted] ស្រុកពួក ខេត្តសៀមរាប នៅលីវ ឪពុកឈ្មោះ [redacted] "វ" ម្ដាយឈ្មោះ [redacted] "វ" ទោសពីមុនគ្មាន។

ឃុំខ្លួនបណ្ដោះអាសន្នចាប់ពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១១ នៅពន្ធនាគារខេត្តសៀមរាប។

-ជនជាប់ចោទឈ្មោះ [redacted] ភេទ ប្រុស អាយុ ៤៩ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិកំពង់តាយ៉ង ឃុំពួក ស្រុកពួក ខេត្តសៀមរាប សាសនាព្រះពុទ្ធ មានទីលំនៅ [redacted] ស្រុកពួក ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] មានកូន ០៥នាក់ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ទោសពីមុនគ្មាន។ (ក្រៅឃុំ)

-ជនជាប់ចោទឈ្មោះ [redacted] សារឿន ភេទ ប្រុស ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិបឹងចេងឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង មានទីលំនៅ [redacted] ស្រុកម៉ាល័យ ខេត្តបន្ទាយមានជ័យ ប្រពន្ធ ឈ្មោះ [redacted] ។ (ក្រៅឃុំ)

-ជនជាប់ចោទឈ្មោះ [redacted] លីណា ហៅ កុយ ភេទ ប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរជាងថតរូប មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅភូមិគោកថ្មី ឃុំពួក ស្រុកពួក ខេត្តសៀមរាប នៅលីវ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ។ (ក្រៅឃុំ)

-ជនជាប់ចោទឈ្មោះ [redacted] នី ភេទ ប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរ មន្ត្រីការពារបរិស្ថាន មានទីកន្លែងកំណើតភូមិគិរីមានុន ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ស្រុកវ៉ារិន ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ទោសពីមុនគ្មាន។ (ក្រៅឃុំ)

មេធាវីការពារសិទ្ធិ លោក [redacted] សុវណ្ណាលី និង លោក [redacted] ឈុនឡេង ។

<u>ជាប់ចោទពីបទ</u> : **កាន់កាប់ និងប្រើប្រាស់អាវុធខុសច្បាប់ និងកំហែងយក** ប្រព្រឹត្តនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្ដីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ និងតាមមាត្រា ៣៦៣ និងមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុធារី ភេទ ស្រី អាយុ ៣៧ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ។

២១៣

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉េត ភេទ ប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិពាមតាអួរ ឃុំកែវពណ៌ ស្រុកពួក ខេត្តសៀមរាប ។

<u>**ឯរឿងហេតុមានដូចតទៅ**</u> ៖

កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង ៦ល្ងាច ឈ្មោះ [redacted] សុផល, ឈ្មោះ [redacted] សីហា, ឈ្មោះ [redacted] នី , ឈ្មោះ [redacted] សៅរី , ឈ្មោះ [redacted] ធឿក, ឈ្មោះ [redacted] សារឿន និងឈ្មោះ [redacted] សីហា បានជិះម៉ូតូចំនួន ០២គ្រឿង ស្លៀកឯកសណ្ឋានយោធា ទៅផ្ទះរបស់ឈ្មោះ [redacted] សុធារី ហើយបានចូលថតឡានដឹកឈើក្រញូង និងបានយកកាំភ្លើង K59 គំរាមយកប្រាក់ចំនួន ១,៥០០ ដុល្លារអាមេរិក ពីឈ្មោះ [redacted] សុធារី ដោយប្រាប់ឈ្មោះ [redacted] សុធារី ថា បើមិនឱ្យប្រាក់ ពួកគេនឹងបញ្ជូនឈ្មោះ [redacted] សុធារី ទៅតុលាការ បន្ទាប់មកឈ្មោះ [redacted] សុធារី បានទូរស័ព្ទហៅឈ្មោះ ម៉ៅ ។ ពេលនោះឈ្មោះ ម៉ៅ មកដល់បានសួរនាំ ហើយ ឈ្មោះ [redacted] សុផល, ឈ្មោះ [redacted] សៅ, និងឈ្មោះ [redacted] សីហា ក៏ត្រូវសមត្ថកិច្ចកងរាជអាវុធហត្ថចាប់ឃាត់ខ្លួន ចំណែកឈ្មោះ [redacted] នី , ឈ្មោះ [redacted] ធឿក , ឈ្មោះ [redacted] សារឿន និងឈ្មោះ [redacted] សីហា បានរត់គេចខ្លួន។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ ៧៨ "គ" ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១២ ដែលមានខ្លឹមសារដូចខាងក្រោម ៖

I/ ឱ្យឈ្មោះ [redacted] សៅរី ហៅ បូរី ភេទ ប្រុស អាយុ ២៨ឆ្នាំ, ឈ្មោះ [redacted] សីហា ភេទ ប្រុស អាយុ ២៤ឆ្នាំ, ឈ្មោះ [redacted] ធឿក ភេទ ប្រុស អាយុ ៤៩ឆ្នាំ, ឈ្មោះ [redacted] លីណា ហៅ កុយ ភេទ ប្រុស អាយុ ៣១ឆ្នាំ រួចខ្លួនពីបទចោទ កាន់កាប់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ និងឱ្យឈ្មោះ [redacted] នី ភេទ ប្រុស អាយុ ៣៥ ឆ្នាំ រួចខ្លួនពីបទចោទ កាន់កាប់ និងប្រើប្រាស់អាវុធខុសច្បាប់ និងកំហែងយក ប្រព្រឹត្តនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ បញ្ញត្តិផ្តន្ទាទោសតាមមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ និងមាត្រា ៣៦៣, មាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ ដែលប្តឹងសុំឱ្យសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៨១១ អ.យ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប និងសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៧៦៧៥/២០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ របស់ចៅក្រមសាលាដំបូងខេត្តសៀមរាប។

តាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងតាមមាត្រា ៣៥០, មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

II/ ក. ផ្តន្ទាទោសលើឈ្មោះ [redacted] សារឿន ភេទ ប្រុស អាយុ ៥០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៤ (បួន) ឆ្នាំ និង០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃចាប់ឃុំខ្លួនបាន និងពិន័យជាប្រាក់ចំនួន ៩,០០០,០០០ (ប្រាំបួនលាន) រៀល

៧១៨

ពីបទ ផ្តើមគំនិត និងសមគំនិតក្នុងអំពើប៉ុនប៉ងកំហែងយក និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២៧, មាត្រា ២៨, មាត្រា ២៩, មាត្រា ៣៦៣, មាត្រា ៣៦៤, មាត្រា ៣៧០, មាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

ខ. ផ្តន្ទាទោសលើឈ្មោះ [redacted] សុផល ភេទ ប្រុស អាយុ ៣១ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ និង០៦ (ប្រាំមួយ) ខែ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១១ និងពិន័យជាប្រាក់ចំនួន ៧,០០០,០០០ (ប្រាំពីរលាន) រៀល។

ពីបទ ប៉ុនប៉ងកំហែងយក និងបទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២៧, មាត្រា ២៨, មាត្រា ២៩, មាត្រា ៣៦៣, មាត្រា ៣៦៤, មាត្រា ៣៧០, មាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

គ. ផ្តន្ទាទោសលើឈ្មោះ [redacted] សៅរី ហៅ បូរី ភេទ ប្រុស អាយុ ២៩ឆ្នាំ និងឈ្មោះ [redacted] សីហា ភេទ ប្រុស អាយុ ២៤ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០៣ (បី)ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១១ និងពិន័យជាប្រាក់ក្នុងម្នាក់ៗកំណត់ចំនួន ៦,០០០,០០០ (ប្រាំមួយលាន) រៀល

ពីបទ ប៉ុនប៉ងកំហែងយក ប្រព្រឹត្តនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១១

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២៧, មាត្រា ២៨, មាត្រា ២៩, មាត្រា ៣៦៣, មាត្រា ៣៦៤, មាត្រា ៣៧០, មាត្រា ៣៧០ នៃក្រមព្រហ្មទណ្ឌ។

ឃ. ផ្តន្ទាទោសលើឈ្មោះ [redacted] ធឿក ភេទ ប្រុស អាយុ ៤៩ឆ្នាំ និងឈ្មោះ [redacted] លីណា ហៅ កុយ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០៣ (បី) ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួនបាន និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ចំនួន ៦,០០០,០០០ (ប្រាំមួយលាន) រៀល

ពីបទ ប៉ុនប៉ងកំហែងយក ប្រព្រឹត្តនៅភូមិចំបក់ហែរ ឃុំពួក ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១១

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២៧, មាត្រា ២៨, មាត្រា ២៩, មាត្រា ៣៦៣, មាត្រា ៣៦៤, មាត្រា ៣៧០, មាត្រា ៣៧០ នៃក្រមព្រហ្មទណ្ឌ។

III. បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] សារឿន , ឈ្មោះ [redacted] ធឿក និងឈ្មោះ [redacted] លីណា ហៅ កុយ ។

តាមមាត្រា ៣៥៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៧១៥

IV/ ច្រានចោលការប្តឹងទាមទារសំណងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉េត។ តាមមាត្រា ៦២, មាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

V/ វត្ថុចាប់យកដែលរក្សាទុកតាមដីកាបង្គាប់ឱ្យរក្សាទុកវត្ថុដែលចាប់យកលេខ១៦១ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ គឺ កាមេរ៉ា SONY ពណ៌សលាយខ្មៅចំនួន ០១គ្រឿង, កាសែតម៉ាកស្វនី ចំនួន ០១, ខោអាវប៉ារ៉ា និងមួក (ចិន) ចំនួន ០២ សម្រាប់, មួកពណ៌ខ្មៅចំនួន ០១, ខ្សែក្រវ៉ាត់សាន់ណេរ៉ុន និងស្រោមកាំភ្លើងខ្លីចំនួន ០១, ខ្សែចង្កេះ (លោហៈធាតុពណ៌ស) ចំនួន ០១, ប័ណ្ណសម្គាល់អាវុធខ្លីចំនួន ០១សន្លឹក, IMMIGRATION CARD ឈ្មោះ [redacted] HACH SANG ថតចម្លងចំនួន ០១សន្លឹក, IMMIGRATION CARD ឈ្មោះ [redacted] MOM MECH ថតចម្លងចំនួន ០១សន្លឹក, គ្រាប់កាំភ្លើងខ្លីចំនួន ០១គ្រាប់, កាបូបដៃចំនួន ០២ ពណ៌ខ្មៅ ចំនួន០១ ពណ៌ប្រផេះ ០១, ម៉ូតូមួយគ្រឿងម៉ាក សេ១២៥ ពណ៌ខ្មៅ លេខតួ និងលេខម៉ាស៊ីន ៨១៦៤៩៨០ ពាក់ផ្លាកលេខ សៀមរាប 1E 1925 , ស្រោមទូរស័ព្ទចំនួន ០១ និងទូរស័ព្ទដៃចំនួន ០៥ គ្រឿង រួមនឹងអាវុធខ្លីម៉ាក K59 ចំនួន ០១ដើម មានលេខ ៣២១ ៨៨៩.៧C ដែលឯកភាពឱ្យប្រើប្រាស់ជាបណ្តោះអាសន្នតាមពាក្យស្នើសុំចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១២ ត្រូវរឹបអូស ចាត់ចែងតាមច្បាប់ ដោយឡែកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំនួន ០១សន្លឹក និង IMMIGRATION ឈ្មោះ [redacted] SANG ថតចម្លងចំនួន ០១សន្លឹក និងច្បាប់ដើមចំនួន ០១សន្លឹក ដែលរក្សាទុកតាមដីកាបង្គាប់ឱ្យរក្សាទុកវត្ថុដែលចាប់បានលេខ ១៦១ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ ហើយវត្ថុចាប់យកពីឈ្មោះ [redacted] នី តាមកំនត់ហេតុទទួលស្គាល់វត្ថុចាប់យក ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១១ របស់អាវុធហត្ថខេត្តសៀមរាប ត្រូវប្រគល់ឱ្យឈ្មោះ [redacted] នី ជាម្ចាស់ដើមវិញ។

តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងតាមមាត្រា ៦២, មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ។

VI/ សាលក្រមនេះ ជំនុំជម្រះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១២ ប្រកាសជាសាធារណៈថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុផល, [redacted] សៅរី ហៅ បូរី, ឈ្មោះ [redacted] សីហា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុធារី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារឿន, [redacted] ធឿក [redacted] លីណា ហៅ កុយ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉េត ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១២ របស់ [redacted] ឈុនឡេង មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សីហា, [redacted] សៅរី និងឈ្មោះ [redacted] សុផល ។

**បានឃើញ** របាយការណ៍រឿង របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី០១/០៤/២០១៣។

**បានឃើញ** សេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៣/០៧/២០១៣។

២១៦

## នាពេលសវនាការ

- ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្តី

- ជនជាប់ចោទ ឈ្មោះ [redacted] សីហា (អវត្តមាន) : តាមអំណានចម្លើយរបស់ជនជាប់ចោទ [redacted] សីហា នៅដំណាក់កាលអយ្យការ (ឯកសារ ៤/៤) បានបញ្ជាក់ថា ខ្លួនបានចុះទៅបង្ក្រាបបទល្មើសដឹកឈើក្រញូងជាមួយឈ្មោះ ផល, ឈ្មោះ ធឿក, ឈ្មោះ បូរី កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ នៅខាងជើងផ្សារពួកដោយសារមានបញ្ជាពីឈ្មោះ [redacted] សារឿន ជាមេរបស់ខ្លួន។ ខ្លួនពុំទាន់មានលិខិតស្នាមជាមន្ត្រីឃោផានៅឡើយទេ គឺលោក [redacted] សារឿន យកចូលក្នុងអង្គភាពរបស់គាត់ ហើយខោអាវ ឯកសណ្ឋាន គឺគាត់ជាអ្នកបើកឱ្យ ។ ខ្លួនចុះទៅនោះ ពុំមានអាវុធកាន់ទេ គ្រាន់តែចុះទៅជាកម្លាំងតែប៉ុណ្ណោះ។

- ជនជាប់ចោទ ឈ្មោះ [redacted] សៅរី (អវត្តមាន) : តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សៅរី នៅដំណាក់កាលអយ្យការ (ឯកសារលេខ ៤/២) បានបញ្ជាក់ថា ខ្លួនបានចុះទៅចាប់ឈើក្រញូងមានគ្នា ០៤នាក់ ហើយខ្លួនពុំមានការងារអ្វីទេ ប៉ុន្តែមានម្នាក់ឈ្មោះ ផល ជាអ្នកបញ្ជាឱ្យឆែកឡាន និង ផ្ទះរបស់គេ។ ខ្លួនចុះទៅ គឺពុំមានអាវុធទេ ឈ្មោះ ផល ទើបមាន ចំណែកឯឯកសណ្ឋាន គឺឈ្មោះ [redacted] សារឿន ជាអ្នកឱ្យដើម្បីចុះ ទៅឆែកឆេរឡាន និងផ្ទះរបស់ប្រជាជន។

- ជនជាប់ចោទ ឈ្មោះ [redacted] សុផល (អវត្តមាន) : តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុផល នៅដំណាក់កាលអយ្យការ (ឯកសារលេខ ៤/១) បានបញ្ជាក់ថា ខ្លួនបានចុះទៅបង្ក្រាបឈើក្រញូងនៅខាងជើងផ្សារពួក ដោយបានឃាត់ឡានដឹកឈើក្រញូងមួយគ្រឿង មានទម្ងន់ ១២០ គីឡូក្រាម ហើយពេលនោះម្ចាស់ដឹកឈើបានសម្រួលថា ឱ្យលុយពួកខ្លួន ប៉ុន្តែមិនទាន់បានទទួលលុយផង ក៏ត្រូវសមត្ថកិច្ចប៉េអឹមឃាត់ខ្លួនតែម្តង ។ នៅពេលចុះទៅបង្ក្រាបនោះ ខ្លួនមានអាវុធ K ៥៩ សៀតនៅនឹងចង្កេះរបស់ខ្លួន ហើយអាវុធនោះមិនមែនជាកម្មសិទ្ធិរបស់ខ្លួនទេ គឺជារបស់មេខ្លួន ឈ្មោះ [redacted] សារឿន គាត់មានតួនាទីស៊ើបអង្កេតប្រចាំនៅយុត្តិភូមិភាគ ហើយគាត់ឱ្យខ្លួនកាន់នៅពេលនោះ គឺពុំមានលិខិតស្នាមកាន់អាវុធដោយខ្លួនឯងទេ ។

- តំណាងមហាអយ្យការសន្និដ្ឋានថា : ពាក្យបណ្តឹងធ្វើឡើងត្រឹមត្រូវតាមច្បាប់ និងយល់ឃើញថាជនជាប់ចោទសារភាពពីទោសកំហុស ដូច្នេះ សុំតម្កល់សាលក្រមរបស់សាលាដំបូងខេត្តសៀមរាបទុកជាបានការដដែល ។

- លោកមេធាវី [redacted] សុវណ្ណាលី បានសន្និដ្ឋានថា: កូនក្តីខ្លួនទាំង៣ បានទទួលបញ្ជារបស់ឈ្មោះ [redacted] សារឿន និងឈ្មោះ [redacted] ធឿក ។ ចំពោះកាំភ្លើងជារបស់ឈ្មោះ [redacted] សារឿន មិនមែនជារបស់កូនក្តីខ្លួនទេ ។ បើពិនិត្យទៅលើសកម្មភាព វាពុំទាន់មានគ្រោះថ្នាក់អ្វីធ្ងន់ធ្ងរទេ រីឯផលប្រយោជន៍ក៏ពុំទាន់បានទទួលដែរ ។ ទោសកំហុសនេះ វាតិចតួចទេ មូលហេតុដែលគាត់ប្រព្រឹត្ត គឺដោយសារគាត់មានជីវភាពក្រីក្រផង ។

៧១៧

សំណូមពរ សុំលោកប្រធានបន្ធូរបន្ថយទោសឱ្យទាបជាងនេះបន្តិច ដើម្បីឱ្យពួកគាត់បានទៅរកស៊ីចិញ្ចឹមកូនប្រពន្ធបន្តទៀត ។

- លោកមេធាវី [redacted] ឈុនឡេង បានសន្និដ្ឋានថា : ខ្លួនសុំឯកភាពតាមការសន្និដ្ឋានរបស់លោកមេធាវី [redacted] សុវណ្ណាលី ដែរ ។ កូនក្តីខ្លួន ទើបតែប្រព្រឹត្តបទល្មើសនេះ ជាលើកដំបូង ខ្លួនសុំឱ្យក្រុមប្រឹក្សាមេត្តាសម្រេចសម្រាលទោសឱ្យកូនក្តីខ្លួន ដោយក្តីអនុគ្រោះ ។

- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានពិនិត្យគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ

- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

យល់ឃើញថា :

១/ តាមពាក្យបណ្តឹងឧទ្ធរណ៍របស់លោក [redacted] ឈុនឡេង មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សីហា, [redacted] សៅរី, និងឈ្មោះ [redacted] សុផល ចុះថ្ងៃទី១៨/០៩/២០១២ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៨ "គ" ចុះថ្ងៃទី២១/០៨/២០១២ របស់សាលាដំបូងខេត្តសៀមរាប ត្រង់សេចក្តីសម្រេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន។

២/ តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សីហា, [redacted] សៅរី និង [redacted] សុផល បានសារភាពថា ពួកខ្លួន ពិតជាមានការពាក់ព័ន្ធនឹងការទាមទារប្រាក់ពីឈ្មោះ [redacted] សុធារី មែន ដោយសារតែបានទទួលបញ្ជាពីឈ្មោះ [redacted] សារឿន ។ ចម្លើយសារភាពនេះ ក្រុមប្រឹក្សាយល់ឃើញថា ជាការភ្ញាក់រលឹក និងដឹងពីកំហុសរបស់ជនជាប់ចោទដែលបានប្រព្រឹត្តខុស។

ការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទ គឺដោយសារតែមានបញ្ជាពីថ្នាក់លើ ដើម្បីជាថ្នូរនឹងការបានចូលក្របខណ្ឌយោធា ។ ក្រុមប្រឹក្សាយល់ឃើញថា ជនជាប់ចោទរៀនសូត្របានតិចតួច មិនមានការយល់ដឹងខ្ពស់ ទើបងាយនឹងចាញ់បោកគេ ម្យ៉ាងទៀតដោយហេតុថា ជនជាប់ចោទមានជីវភាពក្រីក្រផងនោះ គប្បីតុលាការពិចារណាពីស្ថានសម្រាល។

៣/ សំអាងហេតុសាលក្រមព្រហ្មទណ្ឌលេខ ៧៨ "គ" ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តសៀមរាប ដែលបានសម្រេចសេចក្តីមក មានលក្ខណៈត្រឹមត្រូវ សាលាឧទ្ធរណ៍ឯកភាពនឹងសំអាងហេតុរបស់សាលាដំបូង ដូច្នេះសាលាឧទ្ធរណ៍មិនចាំបាច់លើកយកមកសំអាងជាថ្មីទៀតទេ ។

៧១៨

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១/ ទទួលពាក្យបណ្ដឹងឧទ្ធរណ៍របស់លោក [redacted] ឈុនឡេង មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]សីហា, ឆោម សៅរី និងឈ្មោះ [redacted] សុផល ចុះថ្ងៃទី១៨/០៤/២០១២ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២/ តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧៨ "គ" ចុះថ្ងៃទី ២១/០៨/២០១២ លើកលែងតែចំណុចទី II ខ នៃវិនិច្ឆ័យសេចក្ដី ត្រង់ "ផ្ដន្ទាទោសលើឈ្មោះ [redacted] សុផល ដាក់ពន្ធនាគារ ០៣ (បី) ឆ្នាំ ០៦ (ប្រាំមួយ) ខែ" ត្រូវកែប្រែមកជា "ផ្ដន្ទាទោសដាក់ពន្ធនាគារកំនត់ ០២ (ពីរ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ" និងចំណុចទី II គ ត្រង់ "ផ្ដន្ទាទោសលើឈ្មោះ [redacted] សៅរី ហៅ ចូរី និងឈ្មោះ [redacted] សីហា ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ" ត្រូវកែប្រែមកជា "ផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ០២ (ពីរ) ឆ្នាំ ០៦ (ប្រាំមួយ) ខែក្នុងម្នាក់ៗ" ។ ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល។

៣/ បន្តឃុំខ្លួនជនជាប់ចោទ តាមនីតិវិធីច្បាប់ ។

សាលដីកានេះ ត្រូវបានជំនុំជម្រះ និងប្រកាសជាសាធារណៈថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវី។

បើកសិទ្ធិប្ដឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកាស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ... ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]

២១៩